**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តក្រចេះ**
**ស្រុកសំបូរ**
**ឃុំ បឹងចារ**
**លេខ**០០២/១៧ ដឃ

# <u>ដីកា</u>

## <u>ស្តីពី</u>

## ការបង្ការ និង ទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

-បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ច អោយទៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

យោងលិខិតជម្រាបរបស់រដ្ឋបាលខេត្តក្រចេះ លេខ ៨១៣ ល.ក្រច ចុះថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ២០១៥ ស្តីពីការបញ្ឈប់ជាបន្ទាន់មិនអោយផលិតស្រានៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្នុងក្រុង ស្រុកទាំងអស់ ខេត្តក្រចេះ ។

-យោងប្រកាសក្រសួងមហាផ្ទៃលេខ..២៩៣៣ ប្រកា..ចុះថ្ងៃទី..២៧..ខែ..មិថុនា......ឆ្នាំ ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សា មេឃុំ ជំទប់ទី១ ជំទប់ទី២ នៃឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ ។

-យោងលទ្ធផលសិក្ខាសាលាស្តីពី វិធានការរួបរួម ការបង្ការ និង ទប់ស្កាត់អំពើហឹង្សាលើដៃគូស្និតស្នាលដែលជាប់ពាក់ព័ន្ធនិងគ្រឿងស្រវឹង នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៧ ។

-យោងសេចក្តីសំម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំបឹងចារ ស្តីពីវិធានក្នុងការបង្ការ និង ទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង ចុះថ្ងៃទី..២០...ខែ...កក្កដា......ឆ្នាំ..២០១៧....... ។

ដោយមើលឃើញថាបញ្ហាដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹង បានធ្វើអោយមានអំពើហឹង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និង ប៉ះពាល់ដល់សុខភាពជារួមរបស់ប្រជាពលរដ្ឋក្នុងឃុំ បឹងចារ ដូច្នេះ ក្រុមប្រឹក្សាឃុំបឹងចារ

## សម្រេច

**<u>ប្រការ១ ៖</u>** ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រី សិទ្ធិកុមារនិងបង្ការអំពើហឹង្សា ព្រមទាំងលើកកម្ពស់សុខុមាលភាពនិង ប្រាក់ចំណូលប្រជាពលរដ្ឋក៏ដូចជាការរក្សា សន្តិសុខ សណ្តាប់ធ្នាប់ និង សុវត្ថិភាពក្នុងឃុំបឹងចារ ។

**<u>ប្រការ២៖</u>** ដីកានេះមានវិសាលភាពអនុវត្តទៅលើអ្នកប្រើប្រាស់គ្រឿង ស្រវឹងដែលបង្កបញ្ហា ឬ បង្ករការ រំខាន ឬ បង្កហឹង្សានានាំព្រមទាំងការលក់ផលិតផលគ្រឿងស្រវឹងទៅអោយយុវជន ឬ នៅទីកន្លែងមួយចំនួនបក្នុងឃុំបឹងចារ ដែលបានកំណត់ក្នុងដីកា ។

**<u>ប្រការ៣៖</u>** ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង ដល់ ប្រជាពលរដ្ឋ នៅក្នុង

ឃុំបឹងចារតាមវិធីផ្សេងៗ ដូចជា ការជួបជុំបងប្អូន មិត្តភក្តិ ជាពិសេសកម្មវិធីប្រជុំ និង វេទិកាផ្សេងៗនៅក្នុងសហគមន៍។

**ប្រការ៤៖** ព្រះសង្ឃ គណៈកម្មការអាចារ្យវត្ត ចាស់ព្រឹទ្ធាចារ្យ និង នាយកសាលាចូលរួមក្នុង ការបង្កើន ការអប់រំដល់ប្រជាពលរដ្ឋក្នុង សហគមន៍ សាលារៀន និង ពិធីបុណ្យផ្សេងៗ ។

**ប្រការ៥៖** បញ្ចូលកម្មវិធីការទប់ស្កាត់ អំពើហឹង្សាលើដៃគូស្និទ្ធិស្នាល ដោយសារគ្រឿងស្រវឹង ចូលក្នុងកម្មវិធីវិនិយោគ ឬ ផែនការអភិវឌ្ឍន៍ ឃុំបឹងចារ ។

**ប្រការ៦៖** ហាមផ្សព្វផ្សាយ ហាមលក់ និង ហាមសេពគ្រឿងស្រវឹង នៅតាមរបងសាលសរៀន វត្តអារាម សាលាឃុំ ប៉ុស្តិ៍នគរបាលរដ្ឋបាល និង អាគារសាធារណៈរបស់រដ្ឋ ។

**ប្រការ៧៖** ហាមផលិត និង លក់ស្រាសរដែលគ្មានច្បាប់អនុញ្ញាតិ ។ក្នុងករណីដែលបងប្អូន អាជីវកមានបំណងចង់ផលិតស្រាសរត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពី ស្ថាប័នពាក់ព័ន្ធ និង តាមរយៈ មេឃុំ ។

**ប្រការ៨៖** ហាមផ្សព្វផ្សាយរូបភាព ឬ ធ្វើសកម្មភាពបង្ខិតបង្ខំ ឬ ជំរុញលើទឹកចិត្តគ្រប់រូបភាព អោយក្មេងអាយុក្រោម១៨ឆ្នាំ សេពគ្រឿងស្រវឹង នៅក្នុងសហគមន៍ ។

**ប្រការ៩៖** ហាមសេពគ្រឿងស្រវឹងដែលបង្កសំឡេងរំខានដល់អ្នកដទៃ ចាប់ពីម៉ោង ១១ យប់ឡើងទៅ និង ការបង្កភាពតតសណ្តាប់ធ្នាប់ នៅទីសាធារណៈផ្សេង ៗ ក្នុងឃុំ ។ ក្នុង ករណីដែលមានកម្មវិធីចាំបាច់ គឺត្រូវស្នើសុំការនុញ្ញាតពី មេឃុំ ។

**ប្រការ១០៖** ហាមលក់គ្រឿងស្រវឹងអោយជនដែលស្ថិតនៅស្ថានភាពស្រវឹង ។

**ប្រការ១១៖** អាជ្ញាធរ ត្រូវហៅអ្នកប្រព្រឹត្តផ្ទុយពីប្រការ ៦ ,ប្រការ ៧,ប្រការ៨,ប្រការ៩,និងប្រការ ១០ ដើម្បីធ្វើការអប់រំ និងណែនាំ ដោយមានកិច្ចសន្យា ។ ក្នុង ករណី ០៣ លើក អ្នកប្រព្រឹត្តនៅតែមិនអនុវត្តតាមការណែនាំរបស់អាជ្ញាធរ នៅលើកទី ០៤ អាជ្ញាធរ ត្រូវធ្វើការផាកពិន័យជាប្រាក់ ឬ ចាត់វិធានការតាមច្បាប់ ជាធរមាន ។

**ប្រការ១២៖** ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១៧ តទៅ ។

ធ្វើនៅឃុំបឹងចារ,ថ្ងៃទី....០៩.....ខែ សីហា ឆ្នាំ ២០១៧

មេឃុំ

ហ៊ុល សឿង

ចម្លងជូន

- សាលាខេត្តក្រចេះ
- សាលាស្រុកសំបូរ
  (ដើម្បីជូនជ្រាប)
- ក្រុមប្រឹក្សាឃុំ ប៉ុស្តិ៍នគរបាល និង មេភូមិគ្រប់ភូមិ
  (ដើម្បីអនុវត្ត)
- ឯកសារកាលប្បវត្តិ